# រឿង ជីវចិត្តបុណ្យ



# រឿង ដំរីចិត្តបុណ្យ

និពន្ធដោយ អ្នកស្រី ជិន យ៉ាហាន
គូររូបដោយ លោក គឹម សុគន្ធ
រក្សាសិទ្ធិដោយ អង្គការសន្តិស្នេហ៍គ្រចិត្ត(SVA)
បោះពុម្ពឆ្នាំ២០០៩

រឿង

# ដំរីចិត្តបុណ្យ



និពន្ធដោយ ជិន យ៉ាហាន
វិចិត្ររូបភាពដោយ គីម សុគន្ធ
បោះពុម្ពផ្សាយដោយអង្គការសន្តិស្ម័គ្រចិត្ត (អេស.វី.អេ)

នៅខេត្តសៀមរាប ភ្នំបាខែងជាទីកន្លែងកំសាន្តមួយរបស់ភ្ញៀវទេសចរ ។ នៅលើភ្នំនេះមានប្រាសាទបុរាណមួយឈ្មោះថា "ប្រាសាទភ្នំបាខែង" ។ ប្រាសាទនេះបានសាងសង់ឡើង ក្នុងរជ្ជកាលព្រះបាទសុរិយាវរ្ម័នទី ២ នាសតវត្សរ៍ទី១២ ។ ភ្ញៀវទេសចរតែងទៅទស្សនាប្រាសាទភ្នំបាខែង និងជិះដំរីឡើងទៅមើលទេសភាពពីលើកំពូលភ្នំ ជាពិសេសមើលព្រះអាទិត្យហៀបអស្តង្គត ។





ព្រឹកថ្ងៃអាទិត្យនេះ សុភាបានជិះរ៉ឺម៉កម៉ូតូជាមួយអ្នកជិតខាងទៅដល់ជើងភ្នំបាខែង ។ សុភាពោលតែម្នាក់ឯង "យី! ចម្លែកមែន! មើលចុះ មានដឹរីដឹកមនុស្សឡើងលើភ្នំ! យី! ដំរីមានច្រើនម្ល៉េះ? ខ្លះទៅខ្លះមក!"។ បន្ទាប់មក គេក៏ដើរទៅមើលកន្លែងដែលភ្ញៀវឡើងជិះដំរី និងកន្លែងលក់សំបុត្រ ។





សុភាមិនដែលឃើញគេឡើងជិះដំរី ដូចគេឡើងជណ្តើរទៅលើផ្ទះដូច្នេះទេ ។ សុភានិយាយតែម្នាក់ឯងថា អូ! គេឡើងតាមជណ្តើរដែលព័ទ្ធទៅនឹងដើមឈើធំមួយរហូតដល់រានមួយទើបគេឆ្លងទៅអង្គុយលើកូបដំរីតែម្តង បន្ទាប់មកទើបហ្មដំរីបញ្ជាឱ្យដំរីចេញដំណើរ ។






លក់សំបុត្រ

សុភាចង់ជិះដីរីណាស់ តែគេគ្មានប្រាក់ដើម្បីទិញសំបុត្រទេ ។ គេមានប្រាក់តែបន្តិចបន្តួចប៉ុណ្ណោះ ដែលលោកគ្រូតាទើបបានផ្តល់ឱ្យដើម្បីធ្វើដំណើរមកមើលប្រាសាទភ្នំបាខែង ។ សុភាគិតថាគេត្រូវសំចៃប្រាក់នេះទុកខ្លះដើម្បីទិញតែមួយកញ្ចប់ ប្រគេនលោកគ្រូតានៅពេលគេត្រឡប់ទៅភូមិវិញ ។



សុភាឈរសម្លឹងមើលដំរីដែលកំពុងធ្វើដំណើរទៅមកៗ ។ ក្នុងចំណោមដំរីទាំងនោះ មានដំរីមួយក្បាលនេះទឹកមុខគួរឱ្យស្រឡាញ់ជាងគេ ។ វាសម្លឹងមកសុភាយ៉ាងយូរ ឯសុភាក៏សម្លឹងមុខដំរីនោះវិញយ៉ាងយូរដែរ ។





សុភានិយាយតិចៗ "បងដំរីធ្លាប់ស្គាល់ខ្ញុំពីមុនមកឬ?" ។ ដំរីមិនបាន ឆ្លើយតបមកសុភាវិញទេ ។ បន្តិចក្រោយមក វាក៏ចេញដំណើរយឺតៗ អ៊ឹកអ៊ាកៗ ដឹកភ្ញៀវបរទេសវ័យចំណាស់ម្នាក់សំដៅទៅផ្លូវឡើងភ្នំ ។ សុភាសម្រេចចិត្តរត់តាមពីក្រោយដើម្បីបានមើលដំរីមួយនោះឱ្យអស់ចិត្ត ។



លុះបានទៅដល់ចង្កេះភ្នំ ដំរីនោះឈប់ស្ងៀម ឈរទ្រឹង មិនបោះជំហានទៅមុខឡើយ ។ ហ្មដំរីគំរាមព្រមទាំងស្រែកថា ទៅមុខទៀតៗ! មិនទាន់ដល់ទេ! ដំរីនោះនៅឈរទ្រឹងដដែល ឯដំរីផ្សេងទៀតដែលមកពីក្រោយក៏ឈប់តាមដំរីនោះ ហាក់ដូចជាមានបញ្ញាថាអ្នកខាងក្រោយត្រូវគោរពតាមអ្នកនៅខាងមុខ ។ មួយស្របក់ក្រោយមក គេឃើញពួកដំរីឈរបន្តគ្នាជាជួរយ៉ាងវែងព័ទ្ធចង្កេះភ្នំ ។





សុភាងឿងឆ្ងល់យ៉ាងខ្លាំង នៅពេលឃើញដំរីឈរទ្រឹងដូច្នេះ ។ សុភាគិតស្មានថាដំរីឈឺជើង ។ គិតឃើញដូច្នេះសុភាក៏ដើរចេញពីខាងក្រោយទៅខាងមុខដើម្បីពិនិត្យមើលជើងនីមួយៗរបស់ដំរី ។ "ជើងទាំងអស់មិនមានរបួសស្នាមអ្វីទេ តើបងដំរីមានបញ្ហាអ្វី?" សុភានិយាយម្នាក់ឯង ហើយប្រឹងពិនិត្យមើលលើផ្លូវ ក្រែងមានឧបសគ្គអ្វីផ្សេងទៀត ។



នុះន៏! មេចាបចាស់មួយមានរោម និងស្លាបស្ទើរតែគ្របខ្លួនមិនជិត កំពុងតែប្រឹងវារឆ្លងផ្លូវខ្វាសៗដោយជើង និងស្លាបទាំងពីរ ។ សុភាមើលឃើញដូច្នេះក៏រត់ទៅចាប់ទ្រមេចាបដោយថ្នមៗនាំយកទៅដល់ត្រើយម្ខាង ហើយទុកនៅលើសំបុករបស់វា ។ បន្ទាប់មក សុភាក៏រត់មករកដំរីវិញ ។ ដំរីនោះក៏ចាប់បន្តដំណើរទៅមុខ ។ ឯដំរីដែលនៅពីក្រោយ ក៏ចេញដំណើរតាមដែរ ។







លុះធ្វើដំណើរជិតដល់ខ្នងភ្នំ សុភាជំពប់ជើងនឹងដុំថ្ម ហើយដួលក្បែរជើងដំរី ។ ដំរីឈប់ង៉ក់ហើយឈរទ្រឹងទៀត ។ មួយស្របក់ក្រោយមក ដំរីនោះយកប្រមោយត្រកងសុភាមកដាក់លើកូប ។ ភ្ញៀវបរទេសមើលឃើញដូច្នេះ ក៏បង្ខិតខ្លួនឱ្យសុភាអង្គុយក្បែរ ហើយជួយមើលជើងរបួសរបស់សុភាទៀត ។





សុភាភ្លេចឈឹត្រង់ស្នាមរបួសដែលជំពប់នឹងដុំថ្មនៅជើងហើយ ។ គេបានអង្គុយលើខ្នងដំរីប្រឹងទប់ខ្លួនកុំឱ្យយឹកយោកៗ អ៊ឹកអ៊ាកៗតាមដំណើរដំរី ។ "អ៊ីយ៉ា! នៅទីខ្ពស់ដូច្នេះបានឃើញអ្វីៗច្រើនណាស់ នុះន៏! ខ្ញុំបានមកដល់ប្រាសាទភ្នំបាខែងហើយ!" សុភានិយាយតិចៗ ។



ជីវីឈប់ដាក់អ្នកដំណើរនៅវាលមួយដែលស្ថិតមិនឆ្ងាយប៉ុន្មានពីប្រាសាទ

ភ្នំបាខែង ។





បន្ទាប់ពីបានចុះពីខ្នងដំរី សុភាក៏រត់ទៅទិញចេកទុំពីរស្និត និងអំពៅមួយដើមមកបញ្ចុកដំរី ។ ដំរីទំពាចេក បន្ទាប់មកទំពាអំពៅឃ្លុមៗ ។ នៅពេលនោះសុភានិយាយ"ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបងដំរីដែលបានបង្ហាញចិត្តបុណ្យរបស់បងឱ្យខ្ញុំបានឃើញ ។ ខ្ញុំនឹងនឹកដល់បងដំរីជារៀងរហូត" ។/

— ចប់ —





N° 9617[illegible]8



អង្គការសន្តិស្ម័គ្រចិត្ត
Shanti Volunteer Association